# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០២៣ នៅក្រុមហ៊ុន អ៊ីខូ ផាត ខូ អិលធីឌី បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាព លោក សែ វិសេស ជាតំណាងក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារមួយរយ:ដោយមូលហេតុដោយសារ អតិថិជន ផ្អាក ការបញ្ជាទិញលើផលិតផលមួយចំនួន។

សមាសភាពចូលរួម៖

1- ភាគីតំណាងរោងចក្រ

- លោក សែ វិសេស ជាតំណាងនាយករោងចក្រ
- លោក អែម បញ្ញាវឌ្ឍន៍ ជាប្រធានរដ្ឋបាល និងជាអ្នកកត់ត្រា

2- ភាគីតំណាងកម្មករនិយោជិត

- លោក គួ រដ្ឋណាក់ ប្រតិភូពេញសិទ្ធិ
- លោកស្រី ជួន ផល្លី ប្រតិភូពេញសិទ្ធិ
- លោក អាត់ នេត្រា ប្រតិភូជំនួយ
- លោកស្រី ពៅ ចាន់តារា ប្រតិភូពេញសិទ្ធិ

ក្រោយពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោម ៖

1- ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ចំនួន ៣៩ នាក់ ក្នុងចំណោមកម្មករសរុបចំនួន ២០៨ នាក់ ក្នុងរយ:ពេល០២ខែ ដោយគិតចាប់ពីថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣។

2- ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះខាងតំណាងកម្មករទាំងអស់បានឯកភាពគ្នាព្រមទទួលយក ប្រាក់ឧបត្ថម្ភ ដែលក្រុមហ៊ុនផ្តល់ទៅតាមសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភក្នុង កំឡុង ពេលព្យួរកិច្ចសន្យានេះ ។

3- ក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថម្ភ ចំនួន ១០០ដុល្លារអាមេរិក ក្នុងមួយខែនៅថ្ងៃទី ០៥ នៃខែបន្តបន្ទាប់ (ថ្ងៃបើកប្រាក់ឈ្នួលលើកទី០២ របស់កម្មករនិយោជិត)។

4- ចប់ការព្យួរការងារកម្មករនិយោជិត ត្រូវមកចូលធ្វើការនៅកន្លែងដើមវិញ តាមតួនាទីភារកិច្ចរបស់ខ្លួន។

ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១៥:៣០នាទី នាថ្ងៃដដែលក្រោមបរិយាកាសរីករាយ។

ថ្ងៃច័ន្ទ ៩ កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣

បានឃើញនឹងឯកភាព
តំណាងនាយកក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អ៊ីខូ ផាត ខូ អិលធីឌី ECO PARTS CO., LTD. KINGDOM OF CAMBODIA

សែ វិសេស

បានឃើញនឹងឯកភាព
តំណាងកម្មករ

ពៅ ចាន់តារា | គួ រដ្ឋណាក់ | ជួន ផល្លី | អាត់ នេត្រា